ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ : ....៥៨៥០....ប.ទ.អរ.សណ.... ថ្ងៃ អង្គារ ៦កើត ខែ ឆត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២៣

សេចក្តីជូនដំណឹង
ស្តីពី
ការប្រឡងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារ
ក្នុងក្របខណ្ឌក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សម្រាប់ឆ្នាំ២០២៣

យោង : - សេចក្តីណែនាំលេខ៤១៥៧ មស.សណន ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ
- លិខិតលេខ០០៨/២៣ មស.ជម ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងមុខងារសាធារណៈ។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបជូនដំណឹងដល់សាធារណជន និស្សិត និងមន្ត្រីរាជការស៊ីវិលទាំងអស់ឱ្យបានជ្រាបថា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងរៀបចំការប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី ក្របខណ្ឌ "**ក**" ចំនួន ១៨កន្លែង សម្រាប់ឆ្នាំ២០២៣ ដើម្បីបម្រើការងារនៅទីស្តីការក្រសួង ដូចខាងក្រោម៖

- ជំនាញវិទ្យាសាស្ត្រកុំព្យូទ័រ	ចំនួន	៨ កន្លែង
- ជំនាញនីតិសាស្ត្រ	ចំនួន	៤ កន្លែង
- ជំនាញទូរគមនាគមន៍ ឬប្រេកង់ស៊ីវិល	ចំនួន	២ កន្លែង។

ក. លក្ខខណ្ឌនៃការជ្រើសរើស

១. បេក្ខជនត្រូវមានសញ្ជាតិខ្មែរ។

២. បេក្ខជនត្រូវមានសញ្ញាបត្របរិញ្ញាបត្រ សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ សញ្ញាបត្របណ្ឌិត ឬសញ្ញាបត្រសមមូលលើជំនាញនីតិសាស្ត្រ រដ្ឋបាលសាធារណៈ វិទ្យាសាស្ត្រកុំព្យូទ័រ ព័ត៌មានវិទ្យា បច្ចេកវិទ្យាឌីជីថល ទូរគមនាគមន៍ ឬប្រេកង់ស៊ីវិល។

៣. លក្ខខណ្ឌអាយុ (គិតត្រឹមខែមិថុនា ឆ្នាំ២០២៣) ត្រូវបានកំណត់ ដូចខាងក្រោម៖
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ
- បេក្ខជនជាមន្ត្រីរាជការ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ និងត្រូវមានលិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងពីប្រធានក្រសួង-ស្ថាប័នសាមី។ ក្រោយពេលប្រឡងជាប់ជាស្ថាពរ បេក្ខជនត្រូវរៀបចំបែបបទផ្ទេរក្របខណ្ឌពីក្រសួង-ស្ថាប័នសាមី មកបម្រើការងារនៅក្នុងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ហើយបេក្ខជនត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែមិនរក្សាមុខតំណែងទេ។

៤. បេក្ខជនមិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ។

៥. បេក្ខជនជានារី ឬជនមានពិការភាព ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្ត។

៦. សញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សាគ្រប់កម្រិតជំនាញ ត្រូវបានដាក់វិធានការដូចខាងក្រោម៖

- ករណីរកឃើញមានការក្លែងបន្លំសញ្ញាបត្រ ឬលិខិតស្មាមផ្សេងៗ បេក្ខជននឹងត្រូវបានលុបឈ្មោះចេញជាស្ថ័យប្រវត្តិ ទោះបីជាបេក្ខជននោះប្រឡងជាប់ក្នុងក្របខណ្ឌក្រសួងក៏ដោយ
- ចំពោះសញ្ញាបត្រដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវយកទៅបញ្ជាក់ជាភាសាជាតិពីក្រសួងអប់រំ យុវជន និងកីឡា (ករណីពុំទាន់បញ្ជាក់រួច បេក្ខជនអាចយកបង្កាន់ដៃបញ្ជាក់សញ្ញាបត្រនោះ ជំនួសបណ្តោះអាសន្ន)។

ខ. កាលបរិច្ឆេទ និងការទទួលពាក្យ

១. បេក្ខជនត្រូវបំពេញពាក្យស្នើសុំចុះឈ្មោះប្រឡងអនឡាញ តាមរយៈគេហទំព័រ www.form.gov.kh/mptc23 ។

២. កាលបរិច្ឆេទទទួលពាក្យ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

៣. កាលបរិច្ឆេទឈប់ទទួលពាក្យនៅ**ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣** វេលាម៉ោង១២:០០យប់។

គ. សំណុំលិខិតចុះឈ្មោះប្រឡង

១. ពាក្យសុំចុះឈ្មោះប្រឡង (បំពេញតាមអនឡាញ)	ចំនួន ១ច្បាប់។
២. បេក្ខជនត្រូវស្កេនភ្ជាប់មកជាមួយនូវឯកសារយោងនៅពេលបំពេញពាក្យអនឡាញរួមមាន៖	
- សញ្ញាបត្រជំនាញ	ចំនួន ១ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត	ចំនួន ១ច្បាប់
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ	ចំនួន ១ច្បាប់
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន	ចំនួន ១ច្បាប់
- រូបថតទំហំ ៤x៦ (ផ្ទៃស)	ចំនួន ១ សន្លឹក។
៣. បេក្ខជនដែលប្រឡងជាប់ស្ថាពរត្រូវភ្ជាប់មកជាមួយនូវឯកសារតម្រូវរួមមាន៖	
- ជីវប្រវត្តិសង្ខេបមានបិទរូបថត (ទំហំ ៤x៦ ផ្ទៃស)	ចំនួន ១ ច្បាប់
- សណាកបត្រឯកត្តជន	ចំនួន ១ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត	ចំនួន ១ ច្បាប់
- លិខិតថ្កោលទោស	ចំនួន ១ ច្បាប់
- លិខិតបញ្ជាក់សុខភាព	ចំនួន ១ ច្បាប់
- សញ្ញាបត្រជំនាញដោយមានបញ្ជាក់ផ្លូវការពីអាជ្ញាធរមានសមត្ថកិច្ច	ចំនួន ១ ច្បាប់
- កិច្ចសន្យាបម្រើការងារក្រសួង	ចំនួន ១ ច្បាប់
- ឯកសារថតចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនដែលមានបញ្ជាក់	ចំនួន ១ ច្បាប់
- ឯកសារថតចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅដែលមានបញ្ជាក់	ចំនួន ១ ច្បាប់។

ឃ. វិញ្ញាសាប្រឡង

១.វិញ្ញាសាសរសេរ

- ចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (រយៈពេល ២ម៉ោង)
- ភាសាអង់គ្លេស (រយៈពេល ១ម៉ោង និង៣០ នាទី)
- ជំនាញឯកទេស (រយៈពេល ២ម៉ោង)។

២.វិញ្ញាសាសម្ភាសន៍ផ្ទាល់មាត់៖ សម្រាប់បេក្ខជនដែលប្រឡងជាប់វិញ្ញាសាសរសេរ។

ង. កាលបរិច្ឆេទ និងមណ្ឌលប្រឡង

ចំពោះកាលបរិច្ឆេទ និងមណ្ឌលប្រឡង ក្រសួងនឹងជូនដំណឹងនៅពេលក្រោយ។

បញ្ជាក់៖ - ពាក្យស្នើសុំសិទ្ធិប្រឡង និងការដាក់ពាក្យប្រឡង ពុំតម្រូវឱ្យមានការបង់ប្រាក់ទេ

- សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងមកនាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាល រៀងរាល់ម៉ោងធ្វើការ តាមរយៈទូរសព្ទលេខ ០១៧ ៧១៦ ៩២១ / ០១២ ៩២៥ ៩៣៥ ឬអ៊ីមែល hr@mptc.gov.kh ។

អាស្រ័យហេតុនេះ សូមសាធារណជន និស្សិត និងមន្ត្រីរាជការស៊ីវិលទាំងអស់ជ្រាបជាព័ត៌មាន។

ប្រធានគណៈកម្មការរៀបចំការប្រឡង

ជាម សត្ថារតន៍

សូមស្កែន QR Code សម្រាប់៖

ទម្រង់ពាក្យស្នើសុំចុះឈ្មោះប្រឡងអនឡាញ

ឆានែលតេឡេក្រាម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍